# ការសំភាសរបស់ អ្នកមីង ហ៊ុន គឿន

**កៈ អ្នកដែលសំភាសន៍ឈ្មោះ ឡាំ ផារីន ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះ ហ៊ុន គឿន**

## សង្ខេបរបស់លោកពូ ហ៊ុន គឿន

អ្នកមីង ហ៊ុន គឿន គាត់មានអាយុ ៦០ ឆ្នាំក្នុងឆ្នាំ២០១៩។ លោកគាត់មានកូនទាំងអស់ចំនួន ៦នាក់ គាត់ដែលមានទីលំនៅបច្ចុប្បន្ននៅក្នុង ភូមិអង្គ សង្កាត់អូចារ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

កៈ ចឹងជាដំបូងជំរាសួរអ្នកមីងនាងខ្ញុំមកពីខាងសកលវិទ្យាល័យនៃសហរដ្ឋអាមេរិច ហើយគេបានអោយខ្ញុំមកដើម្បីសុំការអនុញ្ញាត្តិដើម្បីសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងថាតើលោកពូអាចផ្តល់ឪកាសដើម្បីអោយខ្ញុំបានសំភាសន៏បានដែលរឺទេអ្នកមីង?

ខៈ ចាស បាន។

កៈ ចាសចឹងអរគុណច្រើនអ្នកមីង ហើយចឹងសំភាសន៏ដោយនាងខ្ញុំមានឈ្មោះថា ឡាំ ផារីន ហើយសំភាសន៏នូវថ្ងៃទី១៦ ខែ ០៣ ឆ្នាំ ២០១៩ ចាសជាដំបូងនាងខ្ញុំចង់សុំស្គាល់ឈ្មោះពេញរបស់លោកពូថាតើអ្នកមីងមានឈ្មោះអ្វីដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ខ្ញុំគឺខ្ញុំមានឈ្មោះថា ហ៊ុន គឿន។

កៈ ចាសនិយាយទៅសំរាប់ឆ្នាំនឹងថាតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយដែលទៅអ្នកមីង?

ខៈ ចាសសំរាប់ខ្ញុំគឺខ្ញុំមានអាយុ ៦០ ឆ្នាំហើយ។

កៈ ចាសនិយាយទៅសំរាប់មើលទៅកាន់អ្នកមីងគឺនៅក្មេងដែល ហើយចឹងចង់សួរអ្នកមីងបន្តិចថាសំរាប់ស្រុកកំណើតរបស់អ្នកមីងថាតើអ្នកមីងមានទីកន្លែងកំណើតនឹងនៅទីកន្លែងណាដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ស្រុកកំណើតរបស់ខ្ញុំនឹងនៅខាងខេត្ត ពោធ៏សាត់។

កះ ចាសហើយចឹងសំរាប់អ្នកមីងគឺជានាក់នៅខាង ពោធិ៍សាត់ មែនដែលរឺទេអ្នកមីង ហើយសំរាប់នៅខាងនឹងគឺជាស្រុកកំណើតរបស់អ្នកមីងតែម្តងមែនដែលរឺទេអ្នកមីង?

ខះ ចាសៗ

កះ ចាសហើយចឹងសំរាប់អ្នកមីងអាចដឹងខ្លះអំពីឃុំរបស់អ្នកមីងដែលរឺទេអ្នកមីង?

ខះ ចាសសំរាប់ឃុំដែលខ្ញុំបានរស់នៅនឹងគឺនៅឃុំ បឹងខ្នា ហើយសំរាប់ភូមិនឹងក៏ភូមិបឹងខ្នាដែល ហើយខេត្តនឹងគឺខេត្ត ពោធិសាត់តែម្តង។

កះ ចាសហើយចឹងចង់សួរអ្នកមីងថាតើសំរាប់អ្នកមីងមានបងប្អូនទាំងអស់ចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង?

ខះ ចាសសំរាប់ខ្ញុំគឺខ្ញុំមានបងប្អូនទាំងអស់នឹងចំនួន ៣នាក់ចឹងហាស តែសំរាប់បងប្អូនរបស់ខ្ញុំនឹងគឺពួកគាត់បានស្លាប់បាត់ទៅហើយ។ ហើយសំរាប់មកដល់លូវនឹងគឺនៅសល់តែខ្ញុំម្នាក់នោះទេ។

កះ ចាសហើយចឹងសំរាប់បងប្អូនរបស់អ្នកមីងថាតើមានប្រុសចំនួនប៉ុន្មាននាក់ ហើយនឹងស្រីនឹងចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង?

ខះ ចាសសំរាប់បងប្អូនរបស់ខ្ញុំនឹងគឺប្រុសចំនួន២នាក់ ហើយប្រុសនឹងគឺត្រូវបានស្លាប់ទាំង២នាក់តែម្តង។

កះ ចាសហើយចឹងសំរាប់ពួកគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង?

ខះ ចាសនិយយាទៅសំរាប់ពួកគាត់បាននាមត្រកូលរបស់តាគាត់។ បងទីមួយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា កង ហឿន ហើយសំរាប់បងទី២របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា កង ហ៊ិន ។ តែសំរាប់ពួកគាត់បានស្លាប់បាត់អស់ហើយ។

កះ ចាសហើយចឹងសំរាប់ពួកគាត់ថាតើពួកគាត់បានស្លាប់នឹងដោយសារតែអ្វីដែលទៅអ្នកមីង?

ខះ ចាសនិយាយទៅសំរាប់ពួកគាត់បានស្លាប់ដោយសារតែជំងឺ។

ក៖ ចាសហើយចឹងគឺមិនអ្វីនោះទេអ្នកមីង ចាសហើយចឹងចង់សួរអ្នកមីងបន្តិចទៀតថាសំរាប់ឪពុកហើយនឹងម្តាយរបស់អ្នកមីងថាតើពួកគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហ៊ុន ហើយសំរាប់ម្តាយរបស់ខ្ញុំគឺគាត់មានឈ្មោះថា ភុយ។

ក៖ ចាសហើយចឹងសំរាប់ឪពុកហើយនឹងម្តាយរបស់អ្នកមីងថាតើពួកគាត់នៅមានជីវិតនៅដែលរឺក៏យ៉ាងមិចដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ពួកគាត់បានស្លាប់បាត់អស់ហើយ។ ហើយសំរាប់ការដែលគាត់បានស្លាប់នឹងគឺស្លាប់តែពីខ្ញុំនៅតូចៗ។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងនៅចាំទេថា នៅពេលដែលឪពុកហើយនឹងម្តាយរបស់អ្នកមីងគាត់បានស្លាប់នឹងថាតើគាត់បានស្លាប់នៅក្នុងអាយុប៉ុន្មានដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់រឿងមួយនឹងគឺយើងមិនបានដឹងនោះទេ។ ហើយនៅពេលដែលគាត់បានស្លាប់នឹងគឺតាំងពីខ្ញុំមិនទាន់នឹងបានដឹងក្តីនោះទេ។ ហើយនិយាយទៅគឺគាត់បានស្លាប់យូរហើយ ហើយសំរាប់ការដែលគាត់បានស្លាប់នឹងគឺស្លាប់តែពីខ្ញុំនៅតូចៗ។

ក៖ ចាសហើយចឹងសំរាប់ពួកគាត់បានឈឺស្លាប់ទាំង២នាក់មែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ

ក៖ ចាសហើយចឹងសំរាប់ឪពុកហើយនឹងម្តាយរបស់អ្នកមីង នៅពេលដែលគាត់បានស្លាប់នឹងថាតើគាត់ដែលបានប្រកបមុខរបបអ្វីដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅពីមុនដែលគាត់មិនទាន់នឹងស្លាប់នឹងគឺគាត់បានប្រកបមុខរបបធ្វើស្រែហើយនឹងធ្វើចំការ។

ក៖ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថា សំរាប់នៅក្នុងជំនាន់នឹង នៅពេលដែលគាត់បានធ្វើការងារចឹងថាតើគាត់ដែលបានអោយកូនរបស់គាត់បានទៅរៀនសូត្រដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់រឿងមួយនឹងគឺមិនដែលនោះទេ។ ពីព្រោះអីនឹងនៅពេលដែលខ្ញុំនៅតូចនឹងគឺខ្ញុំបានដើរទៅរស់នៅជាមួយនឹងអ្នកមីងមារបស់ខ្ញុំតិចៗចឹងទៅ។ ហើយណាមួយទៀតនឹងគឺគាត់បានយកយើងនឹងទៅចិញ្ចឹមទៀត។

ក៖ ចាសហើយចឹងសំរាប់បងៗរបស់អ្នកមីង ថាតើពួកគាត់បានរស់នៅជាមួយនឹងអ្នកមីងរបស់អ្នកមីងដែលមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់បងៗរបស់ខ្ញុំនឹងគឺពួកគាត់បានទៅរស់នៅជាមួយនឹងលោកយាយហើយនឹងរស់នៅជាមួយអ៊ុំចឹងទៅ ហើយនិយាយទៅគឺយើងចែកគ្នារស់នៅចឹងទៅ។ ហើយសំរាប់បងរបស់ខ្ញុំមួយនឹងគឺបានរស់នៅជាមួយនឹងអ៊ុំរបស់ខ្ញុំចឹងទៅ ហើយសំរាប់បង១ទៀតរបស់ខ្ញុំនឹងគឺគាត់បានរស់នៅជាមួយអ្នកមីងរបស់យើងចឹងទៅ។ហើយសំរាប់ខ្ញុំបានរស់នៅជាមួយយាយរបស់ខ្ញុំចឹងទៅ ហើយសំរាប់លោកយាយរបស់ខ្ញុំនឹងគឺគាត់បានដើរតែរស់នៅជាមួយនឹងកូនចៅរបស់គាត់ចឹងទៅ។

ក៖ ចាសហើយចឹងសំរាប់លោកយាយរបស់អ្នកមីងថាតើគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់លោកយាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា អូន។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងរបស់អ្នកមីងនៅក្នុងជំនាន់មុននឹងថាតើគាត់បានប្រកបមុខរបរអ្វីដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់លោកយាយរបស់ខ្ញុំនឹងគឺគាត់មិនបានប្រកបមុខរបរអ្វីនោះទេ។ ហើយសំរាប់គាត់បានស្លាប់តាំងពីជំនាន់ប៉ុលពតមកម្លេស។

ក៖ ចាសហើយចឹងបានន័យថាសំរាប់អ្នកមីងសព្វថ្ងៃនឹង អ្នកមីងបានរស់នៅតែម្នាក់ឯងនោះទេមែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ

ក៖ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថាសំរាប់អ្នកមីង អ្នកមីងមានក្រុមគ្រួសារហើយមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅគឺខ្ញុំមានគ្រួសារហើយ។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងបានរៀបការជាមួយនឹងលោកពូនៅក្នុងឆ្នាំមួយណាដែរឡទៅអ្នកមីង?

ខ៖ ចាសនិយាយទៅគឺយើងបានរៀបការនឹងគឺនៅពេលដែលយើងបានចប់ពេលដែលវៀតណាម គេបានចូលមក។ ហើយយើងនៅក្នុងជំនាន់នឹងគឺមិនដឹងឆ្នាំប៉ុន្មាននោះទេ។ ហើយណាមួយទៀតនឹងគឺយើងមិនសូវជាដឹងនោះទេ។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងនៅពេលដែលបានរៀបការនឹងថាតើ ចាស់ទុំគាត់បានរៀបចំអោយអ្នកមីងដែលមែនដែលរឺទេអ្នកមីង?

ខ៖ ចាស។

ក៖ ចាសហើយចឹងសំរាប់ប្តីរបស់អ្នកមីងថាតើគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង?

ខ៖ ចាសសំរាប់ប្តីរបស់ខ្ញុំគឺគាត់មានឈ្មោះថា ហ៊ាន។

ក៖ ចាសហើយចឹងសំរាប់សព្វថ្ងៃនឹងថាតើគាត់មានព្រះជន្មនឹងប៉ុន្មានដែលទៅអ្នកមីង?

ខ៖ ចាសសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់មានអាយុនឹងប្រហែលជា ៦០ ឆ្នាំជាង។

ក៖ ចាសហើយចឹងសំរាប់ប្តីរបស់អ្នកមីងថាតើគាត់បានប្របកមុខរបបអ្វីដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅគឺប្តីរបស់ខ្ញុំនឹងគឺគាត់បានធ្វើការងារខាងសំណង់។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងមានប្រកបមុខរបបអ្វីដែលរឺទេអ្នកមីង?

ខ ចាសនិយាយទៅសំរាប់ខ្ញុំគឺមិនបានប្រកបមុខរបបអ្វីនោះទេ។ ពីព្រោះអីនឹងគឺខ្ញុំបាននៅផ្ទះហើយចាំដាំបាយអោយប្តីរបស់ខ្ញុំតែប៉ុននឹង។ ហើយសំរាប់ណាមួយទៀតនឹងគឺផ្ទះរបស់យើងជួលគេទៀត។

ក៖ ចាសហើយចឹងនៅពេលដែលអ្នកមីងបានរៀបការជាមួយនឹងប្តីរបស់អ្នកមីងហើយចឹងថាតើ អ្នកមីងសព្វថ្ងៃនឹងអ្នកមីងមានកូនទាំងអស់ចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង?

ខ៖ ចាសនិយយាទៅសំរាប់កូនរបស់ខ្ញុំទាំងអស់នឹងគឺមានចំនួន ៦នាក់។

កៈ ចាសហើយចឹងសំរាប់កូនរបស់អ្នកមីងទាំងអស់មានឈ្មោះអ្វីដែឡទៅអ្នកមីង?

ខៈ ចាសសំរាប់កូនទី១របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថ ឈួន ហើយសំរាប់កូនទី២របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា  ថល ហើយសំរាប់កូនទី៣របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា ហ៊ល ហើយសំរាប់កូនទី៤របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា វីន ហើយសំរាប់កូនទី៥របស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា វុន ។

កៈ ចាសហើយចឹងសំរាប់កូនរបស់អ្នកមីងទាំងអស់ថាតើពួកគាត់មានគ្រួសារអស់ហើយមែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់កូនរបស់ខ្ញុំគឺមានគ្រួសារនឹង៣នាក់ ហើយសំរាប់៣នាក់ទៀតនឹងគឺមិនទាន់មានគ្រួសារនោះទេ។

កៈ ចាសហើយចឹងសំរាប់ផ្ទះរបស់អ្នកមីងថាតើមានទីតាំងនឹងនៅទីកន្លែងណាដែលទៅអ្នកមីង?

ខៈ ចាសសំរាប់ផ្ទះរបស់ខ្ញុំនឹងនៅខាងជើង ។។

កៈ ចាសហើយចឹងបានន័យថាសំរាប់អ្នកមីងគឺជាម្តាយរបស់ បងវុន មែនដែលរឺទេអ្នកមីង?

ខៈ ចាស។

កៈ ចាសនិយាយទៅគឺខ្ញុំបានស្គាល់ដែល។ មែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅគឺគាត់នឹងគឺមានឈ្មោះថា វុន ដែល។

កៈ ចឹងបានន័យថាសំរាប់ផ្ទះរបស់អ្នកមីងគឺមិនមែននៅទីកន្លែងនេះនោះទេមែនដែលរឺទេអ្នកមីង?

ខៈ ចានសំរាប់ផ្ទះរបស់ខ្ញុំនឹងគឺថាគ្រាន់តែថាចេញពីកន្លែងនេះទៅគឺថា យើងបានទៅផ្ទះរបស់ខ្ញុំហើយ។ និយាយទៅគឺយើងដើរបន្តិចនឹងគឺដល់ហើយ។

កៈ ចាសហើយចឹងចង់សួរអ្នកមីងថាសព្វថ្ងៃនឹង អ្នកមីងរស់នៅភូមិឃុំអ្វីដែលទៅអ្នកមីង?

ខៈ ចាសសំរាប់ភូមិដែលខ្ញុំបានរស់នៅនឹងគឺ នៅខាងភូមិអង្គ សង្កាត់អូចារ្យ ខេត្តបាត់ដំបង ។

កៈ ចាសហើយចឹងសំរាប់ផ្ទះរបស់អ្នកមីងដែលបានរស់នៅសព្វថ្ងៃនឹងថាតើ អ្នកមីងបានមានដីរបស់យើងស្រាប់រឺក៏បានជួលគេដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅគឺផ្ទះដីនឹងគឺជារបស់យើងនោះទេហាស គឺមិនបានជួលគេនោះទេ។

កៈ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថា នៅពេលដែលមុនសម័យប៉ុនពត។ ហើយចង់សួរអ្នកមីងបានរស់នៅទីកន្លែងណាដែលទៅអ្នកមីង?

ខៈ ចាសសំរាប់ខ្ញុំពីមុនជំនាន់ ប៉ុលពតនឹងគឺខ្ញុំបានរស់នៅខាង រោងចក្រដូនទាវ ។

កៈ ចាសហើយចឹងបានន័យថាសំរាប់អ្នកមីងបានរស់នៅខាង រោងចក្រដូនទាវ មែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយយាទៅគឺខ្ញុំបានរស់នៅជិតរោងចក្រ នឹងហើយនឹងបានធ្វើការងារស្រែចំការ ។

កៈ ហើយចឹងសំរាប់នៅក្នុងជំនាន់នឹងអ្នកមីងបានរស់នៅជាមួយនឹងនាក់ណាគេដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ពេលនឹងគឺយើងបានរស់នៅជាមួយនឹងកងចល័តអីចឹងទៅ។

កៈ ចាសហើយនិយាយទៅគឺពេលនឹងគឺយើងបានរស់នៅខាង កងចល័ត ទៀតមែនដែលរឺទេអ្នកមីង?

ខៈ ចាសៗ

កៈ ចាសហើយចឹងនៅពេលដែលអ្នកមីងបានទៅរស់នៅចឹងទៅថាតើលោកយាយរបស់អ្នកមីង គាត់បានរស់នៅទីកន្លែងណាដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់លោកយាយរបស់ខ្ញុំនឹងគឺគាត់បានស្លាប់បាត់ហើយ។

កៈ ចាសហើយចឹងចង់សួរអ្នកមីងបន្តិថា សំរាប់ប្តីរបស់អ្នកមីងថាតើគាត់មានស្រុកកំណើតនឹងនៅទីកន្លែងណាដែលទៅអ្នកមីង?

ខ៖ ចាសសំរាប់ស្រុកកំណើតប្ដីរបស់ខ្ញុំគឺគាត់រស់នៅភូមិស្រុកនៅខាងខេត្ត ពោធិ៍សាត់ចឹងហាស ហើយសំរាប់ប្ដីរបស់ខ្ញុំនឹងគឺគាត់បានមករស់នៅបាត់ដំបងរបស់យើងនឹងគឺជាង ២០ ឆ្នាំហើយ។។

ក៖ ចាសហើយចឹងបានន័យថាសំរាប់អ្នកមីងបានមករស់នៅទីកន្លែងនេះនឹងគឺជាង ២០ឆ្នាំហើយមែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ

ក៖ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចទៀតថាសំរាប់ប្ដីរបស់អ្នកមីង ថាតើគាត់មានបងប្អូនទាំងអស់នឹងចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់បងប្អូនប្ដីរបស់ខ្ញុំនឹងគឺគាត់មានចំនួន ៨នាក់ដែល។

ក៖ ចាសហើយចឹងសំរាប់ពួកគាត់មិនបានរស់នៅជិតគ្នានោះទេមែនដែលរឺទេអ្នកមីង?

ខ៖ ចាសគឺពួកគាត់មិនបានរស់នៅជិតគ្នានោះទេ។ ហើយនិយាយទៅសំរាប់ពួកគាត់នឹងគឺបានរស់នៅឆ្ងាយៗដែល។

ក៖ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថា សំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងថាតើអ្នកមីងត្រូវគេបានអោយធ្វើការងារអ្វីខ្លះដែលទៅអ្នកមីង?

ខ៖ ចាសនិយយាទៅសំរាប់នៅក្នុងជំនាន់នឹងគឺគេបានអោយយើងនឹងធ្វើការងារដូចជា លើកប្រឡាយ ហើយនឹងដកស្ទុងអី។

ក៖ ចាសហើយចឹងបានន័យថាសំរាប់អ្នកមីងនៅពេលដែលគេបានជំលៀសអ្នកមីងមកចឹងគឺគេបានជំលៀសអ្នកមីងមកពីខាងដូនទាវមកមែណដែលរឺទេអ្នកមីង?

ខ៖ ចាសៗនឹងហើយចាស ហើយនិយាយទៅគឺគេបានយកយើងនឹងអោយយើងនឹងធ្វើការងារខាងនៅខាងរោងចក្របាររបស់គេ។ ហើយយនៅពេលដែលយើងបានមកចឹងគឺមានវៀតណាមគេបានចូលមកជួយរំដោះយើងចឹងទៅក៏យើងនឹងបានរត់ចូលក្នុងភូមិស្រុករបស់យើងវិញចឹងទៅ។

កៈ ចាសហើយចឹងនៅពេលដែលគេបានជំលៀសអ្នកមីង មកខាងខេត្តបាត់ដំបង មកចឹងថាតើគេបានអោយមកនឹងដោយសារអ្វីដែលទៅអ្នកមីងរឺក៏អ្នកមីងបានដើរមក ឬរឹក៏មានអ្វិសំរាប់ជិះដែលទៅអ្នកមីង?

ខៈ ចាសនិយយាទៅនៅពេលដែលគេបានជំលៀសយើងមកនឹងគឺគេបានអោយយើងនឹងជិះឡាន មក។ ហើយសំរាប់គេបានទៅយកយើងនឹងចេញភូមិតែម្តង។

កៈ ចាសហើយចឹងនៅពេលដែលគេបានយកអ្នកមីងមកនឹងគឺមានមនុស្សច្រើនដែលរឺទេអ្នកមីង ដែលបានចេញពីភូមិនឹងមកចឹងនឹងអ្នកមីង?

ខៈ ចាសនិយយាទៅនៅពេលដែលគេបានយកយើងចេញពីភូមិនឹងគឺច្រើនដែលប្រហែលជាមានគ្នានឹងគឺចំនួន ៧០នាក់ដែល។

កៈ ចាសហើយចឹងសំរាប់គេថាតើគេបានយកវ័យដែលចេញពីភូមិនឹងប្រហែលជាវ័យមួយណាដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅគឺគេបានយកអាយុនឹងប្រហែលជា ១៦ ទៅ ១៨ ឆ្នាំ។

កៈ ចាសហើយចឹងបានន័យថាសំរាប់គេបានយកវ័យតែប៉ុននឹងដើម្បីនឹងយកមកធ្វើការងារនៅក្នុងជំនាន់នឹងមែនដែលរឺទេអ្នកមីង?

ខៈ ចាសៗ

កៈ ចាសហើយចឹងសំរាប់នៅក្នុងជំនាន់នឹងនៅពេលដែលគេបានធ្វើការងារនឹងនៅខាង រោងចក្រនឹងថាតើការងារនៅក្នុងនឹងមានការងារអ្វីខ្លះដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់នៅក្នុងនឹងគឺគេបានអោយយើងនឹងការងារខាងតម្បាញ់បារចឹងទៅ។ ហើយសំរាប់ពេលនឹងគឺគេមានសឹកទី១ ហើយនឹងសឹកទី២។ ហើយនិយាយទៅគឺគេបានអោយយើងនឹងធ្វើខ្មៅចឹងទៅ។ហើយសំរាប់នាក់ដែលធ្វើកន្ទងៗចឹងទៅ។ ហើយនិយាយទៅគឺគេមានការងារនឹងគឺផ្សេងៗគ្នាចឹងហាសហើយគឺគេបានចែកដាច់ពីគ្នាតែម្តង។ ណាមួយទៀតនឹងគឺគេមានមួយក្រុមៗរបស់គេចឹងទៅ។

កៈ ចាសហើយចឹងសំរាប់នៅក្នុងមួយក្រុមនឹងថាយើងនឹងមានគ្នានឹងចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់មួយក្រុមនឹងគឺមានគ្នានឹងគឺច្រើនដែលចឹងហាចាស ហើយដូចថាមួយកងនឹងគឺមានគ្នាចំនួន ២០ ទៅ៣០នាក់ចឹងទៅ។ តាមនឹងចឹងទៅ។

កៈ ចាសហើយនៅពេលដែលមានការងារនឹងគឺគេបានបែងចែកការងាររបស់យើងដាច់ពីគ្នាតែម្តង មែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ដូចជាក្រុមរបស់ខ្ញុំនឹងគឺគេបានដាក់អោយយើងនឹងមាន ម៉ាស៊ីនមួយចឹងទៅដាច់ពីគេចឹងទៅ។ ហើយសំរាប់ម៉ាស៊ីនខ្លះនឹងគឺគេបានដាក់មួយ៣នាក់អីចឹងទៅហាស ហើយណាមួយទៀតនឹងគឺគេបានបែងចែកនឹងគឺដាច់ពីគ្នាតែម្តង។

កៈ ចាសហើយចឹងសំរាប់គេបានបានដាក់កំណត់ អោយយើងនឹងធ្វើការងារនៅក្នុងមួយថ្ងៃនឹងគឺយើងត្រូវត្បាញ់បារអោយគេបានប៉ុន្មាននៅក្នុងមួយថ្ងៃនឹងថាតើមានដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ពេលនឹងគឺដូចថាគេមានកងគេផ្សេងចឹងទៅ។ ហើយសំរាប់មួយនឹងគឺគេបានកំណត់របស់គេ។ ហើយសំរាប់ខាងរបស់ខ្ញុំនឹងគឺគេបានអោយយើងនឹងធ្វើសឹក។

កៈ ចាសហើយចឹងសំរាប់សឹកនឹងគឺយ៉ាងមិចដែលទៅអ្នកមីង?

ខៈ ចាសសំរាប់សឹកនឹងគឺគេបានធ្វើកាខ្មៅ។ ហើយសំរាប់ខ្មៅរបស់គេនឹងគឺគេបានបោះចឹងទៅគឺគេបានដាក់អោយម៉ាស៊ីននឹងដើម្បីកិនទៅគឺធ្វើអោយម៉ត់ចឹងទៅ។

កៈ ចាសហើយចឹងបានន័យថាសំរាប់យើងនឹងគឺនៅចាំឈរបោះ ខ្មៅនឹងដើម្បីបោះចូលទៅក្នុងម៉ាស៊ីននឹងតែម្តងមែនដែលរឺទេអ្នកមីង?

ខៈ ចាសៗ។

កៈ ចាសហើយចឹងសំរាប់ការងារទាំងអស់នឹង នៅពេលដែលគេបានអោយយើងនឹងធ្វើចឹងទៅថាតើគេមានម៉ោងដើម្បីអោយយើងនឹងបានសម្រាក់ដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់យើងនៅពេលដែលចូលម៉ោងធ្វើការងារនឹង ចាប់ផ្តើមនឹងគឺពេលព្រឹក ហើយនឹងពេលល្ងាចម៉ោងប្រហែលជា ៥ អីនឹងគឺយើងបាននាំគ្នានឹងគឺដើម្បីជំរង់ជួលហើ

យ។ ហើយសំរាប់ម៉ោង ៥ជាងនឹងគឺគេបានចូលធ្វើការងារហើយ។ ហើយសំរាប់ម៉ោង ១១ ចេញ ហើយសំរាប់ម៉ោង១ចូល ហើយសំរាប់ម៉ោង ៥អិនឹងគឺយើងបានចេញមកផ្ទះរបស់យើងវិញ។

ក៖ ចាសហើយចឹងសំរាប់នៅក្នុងជំនាន់នឹង សំរាប់ការងាររបស់យើងនឹងគឺគេបានកំណត់អោយយើងតែម្តង ហើយសំរាប់គេមិនបានអោយយើងនឹងធ្វើការងារនឹងដល់ពេលយប់នោះទេមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយយាទៅសំរាប់ពេលយប់នឹងគឺថាត្រឹមម៉ោង ៦ល្ងាចនឹងគឺធ្វើការងាររហូតដល់ម៉ោង ១០យប់។

ក៖ ចាសហើយចឹងបានន័យថាសំរាប់ការងារនឹងគឺគេបានដាក់បន្ថែមអោយយើងនឹងធ្វើការងារទៀតមែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ

ក៖ ចាសហើយចឹងសំរាប់ការងារទាំងអស់នឹងថាតើគេបានអោយយើងនឹងហូបចុកនឹងគ្រប់គ្រាន់ដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ការងារនៅក្នុងរោងចក្រនឹងគឺយើងហូបទៅគឺបានគ្រប់គ្រាន់។ តែសំរាប់យើងដែលបានរស់នៅខាងកងចល័តនឹងគឺយើងហូបទៅគឺមិនបានគ្រប់គ្រាន់នោះទេ។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងថាតើអ្នកមីង បានធ្វើការងារនៅខាងរោងចក្រតម្បាញ់នឹងប្រហែលជាប៉ុន្មានឆ្នាំដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ខ្ញុំនឹងគឺមិនសូវជាបានដឹងនោះទេ។ និយយាទៅគឺមិនដឹងថាយើងនឹងបានរស់នៅប៉ុន្មានឆ្នាំនោះទេ តែគ្រាន់តែដឹងថាពេលនឹងគឺវៀតណាមគេបានចូលមក។

ក៖ ចាសហើយចឹងសំរាប់អ្នកមីង ពីមុនដែលអ្នកមីងបានចូលធ្វើការងារនៅខាងរោងចក្រតំម្បាញ់នឹងថាតើពីមុននឹងទៀតអ្នកមីងមានបានធ្វើការងារអ្វីផ្សេងទៀតដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅគឺដូចជាអត់មាននោះទេ។ ហើយនិយាយទៅគឺយើងបានធ្វើការងារនៅខាងក្នុងរោងចក្រនឹងនោះទេ។

កៈ ចាសហើយចឹងអត់មានការងារអ្វីផ្សេងក្រៅពីការងារតម្បាញ់នោះទេមែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅគឺអត់មាននោះទេ។ ។

កៈ ចាសហើយចឹងនៅពេលដែលយើងនឹងបានធ្វើការងារចើង ថាតើគេដែលបានស្តី រឺក៏ថាអោយយើងនឹងអំពីការងាររបស់យើងដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅគឺគេបានស្តីអោយដែលចឹងហាស ហើយគេមានការប្រជុំនៅក្នុងមួយសប្តាហ៍នឹងគឺមួយដងចឹងទៅហើយគេបានស្តីថាអោយយើងចឹងទៅ។ ហើយសំរាប់មួយនឹងគឺដូចថាគេបានហៅថា កសាង។ ហើយនិយយាទៅគឺគេបានកសាងយើងថាអោយយើងអីចឹងទៅ។

កៈ ចាសហើយចឹងសំរាប់កសាងនឹងគឺគេបាននាំយើងនឹងអោយទៅកន្លែងរបស់គេ រឺក៏យ៉ាងមិចដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ការប្រជុំនឹងគឺគេមានគ្នានឹងចំនួន ១០នាក់អីចឹងទៅ។ ហើយគេបានណែនាំយើងថាសំរាប់មិត្តនារីម្នាក់នេះនឹងគឺត្រូវបានធ្វើខុសអីចឹងទៅ។ ហើយសំរាប់មិត្តនារីនឹងគឺត្រូវបានចេញពីការងារអីចឹងទៅ។ ហើយមិនបានធ្វើការងារអីចឹងទៅ។ ហើយសំរាប់មួយនឹងគឺគេបានហៅថាកសាងយើងហើយ។

កៈ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថាសំរាប់អ្នកមីងនៅក្នុងជំនាន់នឹង ថាតើអ្នកមីងបានធ្លាប់ធ្វើកំហុសខុសខ្លះដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់រឿងខុសនឹងគឺតែងតែមានខ្លះហើយ។ ហើយដូចថាយើងនៅក្នុងជំនាន់នឹងគឺយើងបានធ្វើការងារហើយចឹងគឺយើងបានដើរមកនឹងគឺយឺតពេលខ្លះនឹងគឺយើងតែងតែមានហើយចឹង ពីព្រោះអីនឹងនៅក្នុងជំនាន់នឹងគឺយើងនៅក្មេងដែល។សំរាប់ការដើរលេងរបស់យើងនឹងគឺមានខ្លះហើយ ហើយនិយាយទៅគឺយើងបានដើរតាមចំការ ហើយនឹងដើរកាត់ភុកនឹងគឺគេបានស្តីអោយយើងខ្លះហើយ។

កៈ ចាសហើយចឹងសំរាប់នៅក្នុងសម័យប៉ុលពតនឹង សំរាប់អ្នកមីងមានអាយុនឹងប្រហែលជាប៉ុន្មានឆ្នាំដែលទៅអ្នកមីង?

ខៈ ចាសនិយយាទៅសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងគឺខ្ញុំមានអាយុ នឹងប្រហែលជា ១៧ឆ្នាំហើយ។

កៈ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថា នៅពេលដែអ្នកមីងបានដើរទៅធ្វើការងារនឹងថាតើអ្នកមីងគេគ្រាន់តែស្ដីអោយអ្នកមីងនោះទេមែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅសំរាំបប្ដីរបស់ខ្ញុំនៅពេលនឹងគឺគាត់បានអោយខ្ញុំនឹងទៅធ្វើដែលចឹងចាស។

កៈ ចាសហើយចឹងសំរាប់ការហូបចុកនឹងថា គេបានអោយយើងនឹងហូបចុកនឹងប៉ុន្មានដងដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ការហូបនឹងគឺគេបានអោយយើងនឹងហូបតែព្រឹក ហើយនឹងពេលល្ងាចតែប៉ុននឹង។ ហើយសំរាប់ពេលព្រឹកនឹងគឺម៉ោងប្រហែលជា ១១ នឹងគឺគេបានអោយយើងនឹងហូបហើយ។ ហើយសំរាប់ពេលល្ងាចនឹងគឺថាម៉ោង ៥ នឹងគឺគេបានអោយយើងនឹងហូបតែប៉ុននឹង។

កៈ ចាសហើយចឹងសំរាប់ការហូបនឹងថាតើគេបានអោយ ម្ហូបអោយយើងហូបដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅគឺគេបានអោយម្ហូបអោយយើងនឹងហូបចឹងទៅ។ គឺដូចជាសំម្លរប្រហើលអីចឹងទៅ។ ហើយនៅពេលដែលគែបានអោយយើងនឹងហូបនឹងគឺថាចុងភៅរបស់គេនឹងបានធ្វើអោយយើងហូប។ហើយគ្រាន់តែថាសំរាប់គេនៅពេលដែលគេបានវៃជួងចឹងទៅគឺថាដល់ម៉ោងចឹងទៅគឺយើងបានចេញមកពីរោងចក្រចឹងទៅគឺយើងបានឈរជំរង់ជួរគេចឹងទៅ ហើយយើងក៏បានចេញមកកន្លែងដែលគេបានអោយម្ហូបយើង។ហើយសំរាបចុងភៅនឹងគឺយើងអាចហូបបាន។

កៈ ចាសហើយចឹងបានន័យថាសំរាប់យើង អោយតែដល់ម៉ោង ៥នឹងគឺគេដឹងតែអោយម្ហូបអោយយើងហូបហើយមែនដែលរឺទេអ្នកមីង?

ខៈ ចាសៗនិយយាទៅសំរាប់ម៉ោង៥នឹង គឺយើងបានចេញពីធ្វើការងារនឹងគឺទំរាំតែយើងបានដើរមកដល់ទៀតនឹងគឺប្រហែលជា ម៉ោង ៦ ហើយ។បានយើងបានហូប។

កៈ បាទហើយចឹងបានន័យថាសំរាប់កន្លែងការងាររបស់យើងនឹងគឺនៅឆ្ងាយមែនដែលរឺទេអ្នកមីង?

ខ៖ ចាសហើយនិយយាទៅសំរាប់កន្លែងដែលធ្វើចុងភៅ នឹងគឺឆ្ងាយដែល។ហើយនិយយាទៅគឺប្រហែលជា ២០០ ទៅ ៣០០ម៉ែត្រដែលចឹងហាសពីកន្លែងដែលយើងបានធ្វើការងារ។

ក៖ ចាហើយចឹងសំរាប់កន្លែងរបស់ចុងភៅ នឹងគឺគេនៅឆ្ងាយណាស់មែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗនិយាយទៅគឺឆ្ងាយគួរសមដែល។

ក៖ ហើយចឹងសំរាប់កន្លែងដែលបានធ្វើម្ហូបនឹង ថាតើគេបានមកពីណាដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅគឺដូចថានៅកន្លែងរបស់គេនឹងគឺគេបានផ្តល់អោយយើង។ ហើយសំរាប់យើងនឹងគឺយើងមិនសូវជាបានដឹងច្រើននោះទេ។ ហើយនិយាយទៅគឺយើងគ្រាន់តែបានដឹងថានៅពេលដែលយើងបានចេញពីធ្វើការងារនឹងគឺយើងបានហូបម្ហូបអីចឹងទៅ។ និយាយទៅគឺយើងបានដឹងតែប៉ុននឹង។

ក៖ ចាសហើយចឹងសំរាប់នៅក្នុងជំនាន់នឹងថាតើគេដែលបានអោយអ្នកមីងដែលបានទៅលេងឪពុកហើយនឹងម្តាយរបស់អ្នកមីងដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅគឺគេមិនដែលអោយយើងនឹងបានទៅលេងពួកគាត់នោះទេ។ ហើយនៅពេលដែលវៀតណាមគេបានចូលមកចឹងគឺបានយើងនឹងបានរត់ទៅតែម្តង។

ក៖ ចាសហើយចឹងនៅពេលដែលយើងបានរំដោះហើយចឹងថាតើនៅពេលនឹងគឺយើងបានរត់ទៅដោយខ្លួនរបស់យើង រឺក៏គេបានលួចទៅលេងឪពុកហើយនឹងម្តាយរបស់អ្នកមីងដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺដូចថាសំរាប់ស្រុករបស់យើងនឹងគឺមានសន្តិភាព ហើយ។ហើយដល់ពេលចឹងគឺគេបានអោយយើងនឹងទៅនឹងឹចងទៅ។

ក៖ ចាសហើយចឹងនៅពេលដែលយើងទៅនឹងគឺយើងធ្វើដំណើរដោយអ្វីដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅគឺយើងមានតែដើរនោះទេ។ ហើយសំរាប់ពេលនឹងគឺយើងដើរនឹងគឺដើរមានគ្នា។ ហើយដូចថាសំរាប់យើងនឹងគឺមានគ្នានាក់ស្រុកភូមិដែលបានរស់នៅជាមួយគ្នា។ ហើយនិយយាទៅគឺគេមានមិត្តនារីនឹងគឺដូចគ្នា។ ហើយសំរាប់យើងមានចាស់មានក្មេងចឹងទៅ។ ហើយយើងចេះតែដើរជាមួយនឹងគ្នាចឹងទៅ។ ហើយនិយាយទៅគឺយើងដើរចឹងតៅ។

កៈ ចាសហើយចឹងសំរាប់អ្នកមីង ថាតើអ្នកមីងបានដើរប៉ុន្មានថ្ងៃដែលទៅអ្នកមីងបានអ្នកមីងបានដើរទៅកន្លែងដែលអ្នកមីងចង់ទៅដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ពេលនឹងគឺយើងបានដើរនឹងគឺប្រហែលជាដើរជិត ១០ថ្ងៃដែល។

កៈ ចាសនិយាយទៅគឺយូរខ្លាំងណាស់អ្នកមីង ហើយចឹងនៅពេលដែលអ្នកមីងបានដើរចឹងថាតើអ្នកមីងបានអ្វីសំរាប់ហូបដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់ពេលនឹងគឺគេបានបើកជាអង្ករអោយយើងសំរាប់ហូបចឹងហាសដចាស ហើយនិយយាយទៅគឺជាពោតសំលីរបស់គេ។ហើយនៅពេលដែលគេបានបើកអោយយើងចឹងទៅ ហើយដូចថាសំរាប់ពេលថ្ងៃចឹងទៅគឺប្រហែលជាម៉ោង១០ជាងអីចឹងគឺយើងបានសម្រាកនៅទីកន្លែងណា គឺយើងបានដាំបាយសំរាប់ហូបនឹងនៅទីកន្លែងនឹងតែម្តងហាសដចាស ហើយនិយាយទៅនៅពេលដែលយើងបានដាំហូបហើយចឹងគឺយើងបានសម្រាកបន្តិចចឹងទៅក៏យើងបានបន្តដើរទៅមុខទៀតចឹងទៅ។ ហើយនិយាយទៅសំរាប់នៅក្នុងជំនាន់នឹងគឺយើងបានដើររហូតដល់ពេលល្ងាច។

កៈ ចាសហើយចឹងនៅពេលដែលយើងបានសម្រាក ហើយនឹងបានដាំបាយចឹងថាតើយើងមានអ្វីសំរាប់ដាំហូបដែលទៅអ្នកមីង រឺក៏យើងមានចានឆ្នាំងមកជាមួយនឹងដែលទៅអ្នកមីង?

ខៈ ចាសហើយនិយាយទៅសំរាប់នៅពេលនឹងគឺយើងមានសាក់ការដូស្តាយចានឆ្នាំរបស់យើងចឹងទៅ។

កៈ ចាសហើយចឹងសំរាប់អ្នកមីង នៅពេលដែលអ្នកមីងបានដាំបាយចឹង ថាតើនៅពេលដែលដាំនឹងអ្នកមីងមានហូបតែម្នាក់ឯងរឺក៏មានគ្នាដើម្បីនឹងហូបជាមួយអ្នកមីងដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅគឺដូចថាយើងនឹងមានគ្នាចឹងទៅ ហើយប្រហែលជា៩នាក់ចឹងទៅហាសហើយយើងបានស្គាល់គ្នាចឹងទៅហើយយើងក៏បានរួមដំណើតជាមួយគ្នាចឹងទៅ។ ហើយនៅពេលដែលយើងហូបហើយចឹងក៏បានបន្តដំណើរនឹងគឺទៅមុខទៀត។ ហើយដូចថានៅពេលដែលយើងបានរកកន្លែងដែលចាស់ៗនឹងគឺសំរាប់សម្រាកចឹងទៅ។

កៈ ចាសហើយចឹងនៅពេលដែលយើងបានរកកន្លែងសម្រាកនឹងគឺយើងបានសម្រាកនឹងគឺនៅកណ្តាលវាលតែម្តងមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ពេលខ្លះនឹងគឺយើងបានសម្រាកនឹងគឺនៅចំកណ្ដាលវាលចឹងទៅហើយគេក៏បានធ្វើផ្លូវថ្មលទៀតចឹងហាសចាសា ហើយណាមួយទៀតនឹងគឺយើងខ្លាចថាសំរាប់ពួកវៀតណាមគេបានចូលមកចឹងហាសគឺយើងខ្លាចដែល។ ហើយសំរាប់នៅទីកន្លែងណាដែលមានចាស់ៗគាត់មានគ្នាច្រើនចឹងគឺយើងសុំពួកគាត់ដើម្បីបានសម្រាកជាមួយឹនងពួកគាត់។ ។

ក៖ ចាសហើយចឹងនៅពេលដែលយើងបានធ្វើដំណើរតាមផ្លូវចឹងទៅថាអ្នកមីងដែលបានជួបបញ្ហា លំបាកអ្វីដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅនៅពេលដែលធ្វើដំណើតនឹងគឺមិនអ្វីដែល។

ក៖ ចាសហើយនិយាយទៅគឺយើងមិនបានឃើញអ្វីដែលប្លែកអ្វីៗនោះទេមែនដែលរទេអ្នកមីង?

ខ៖ ចាសនិយយាទៅគឺមិនដែលឃើញដែល។

ក៖ ចាសហើយចឹងនៅពេលយើងបានដើរដល់ស្រុករបស់យើងចឹងទៅ ថាតើយើងបានជួបជុំបងប្អូនរបស់យើងដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅនៅពេលដែលយើងបានទៅស្រុករបស់យើងនឹងគឺយើងបានជួប នឹងបងប្អូនរបស់យើងដែល។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងបានជួបជាមួយឹនងបងប្អូនរបស់អ្នកមីងដែលមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅគឺយើងបានជួបគ្នា។

ក៖ ចាសហើយចឹងដូចថាសំរាប់អ្នកមីងបានដើរមកចឹងគឺមិនបានជួបជាមួយបងប្អូនអ្នកមីងនោះទេដូចជាអ្នកមីងបានមកបាត់ដំបងចឹងហាសអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់មួយនឹងគឺយើងមិនបានជួបគាត់នោះទេ។ ពីព្រោះអីនឹងគឺសំរាប់គាត់នៅខាងខេត្ត ពោធិ៏សាត់។

ក៖ ចាសហើយចឹងនៅពេលដែលគាត់នៅខាងខេត្ត ពោធិ៍សាត់ចឹង ថាតើគាត់បានដឹងដំណឹងរបស់អ្នកមីងដែលមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺយើងបាននាំគ្នាដើររកគាត់។ ហើយក៏យើងបានជួបពួកគាត់ទាំង២នាក់តែម្តង។

ក៖ ចាសហើយចឹងបានន័យថាសំរាប់បងប្អូនរបស់អ្នកមីង គឺគាត់មិនបានស្លាប់នៅក្នុងជំនាន់ប៉ុលពតនោះទេមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់បងប្អូនរបស់ខ្ញុំគឺគាត់មិនបានស្លាប់នៅក្នុងជំនាន់ប៉ុលពត នោះទេ គឺគាត់បានស្លាប់នៅក្នុងសម័យនេះលូវៗនោះទេ។ ហើយនិយាយទៅគឺគាត់ស្លាប់ប្រហែលជា៩ឆ្នាំ។

ក៖ ចាសហើយចឹងសំរាប់គាត់បានរស់នៅខាងណាវិញដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅគឺគាត់បានរស់នៅខាងខេត្ត ពោធិ៍សាត់។

ក៖ ចាសហើយចឹងបានន័យថាសំរាប់គាត់បានរស់នៅខាងខេត្ត ពោធិ៍សាត់ នឹងគឺគាត់មានប្រពន្ធហើយនឹងកូនដែលមែនដែលរឺទេអ្នកមីង?

ខ៖ចាសៗ

ក៖ ចាសហើយបានន័យថាសំរាប់គាត់ទើបតែស្លាប់លូវនឹងនោះទេ តែគ្រាន់តែថាសំរាប់អ្នកមីងដែលបានទៅលេងពួកគាត់ដែលរឺទេអ្នកមីង នៅពេលដែលអ្នកមីងបានមករស់នៅខាងខេត្តបាត់ដំបងដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់យើងបានធ្លាប់ទៅលេងពួកគាត់ដែល។

ក៖ ចាសហើយចឹងសំរាប់មូលហេតុអ្វីដែលទៅបានជាអ្នកមីងមករស់នៅបាត់ដំបងដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់យើងនឹងគឺដូចថាជាអត់ពេកចឹងទៅ ហើយយើងបានធ្វើស្រែចំការរបស់យើងនឹងគឺអត់មាន។ហើយដល់ពេលចឹងគឺយើងក៏មានបងប្អូនរបស់យើងនៅខាងខេត្ត

បាត់ដំបងដែល។ ហើយនៅពេលដែលបងប្អូនរបស់យើងនឹងគឺគាត់បានបបួលយើងមករស់នៅចឹងក៏យើងបានមករស់នៅតែម្តង។។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងនៅខាងខេត្ត បាតដំបងអ្នកមីងមានបងប្អូនដែលមែនដែលរឺទេអ្នកមីង?

ខ៖ ចាស១

ក៖ ចាសហើយចឹងបានន័យថាសំរាប់បងប្អូនរបស់អ្នកមីងគឺមិនមែនជាបងប្អូនបង្កើតនោះទេមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ពួកគាត់គឺជាបងប្អូនជីដូនមួយរបស់យើង។

ក៖ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថានៅពេលដែលអ្នកមីងបានរស់នៅខាងខេត្តបាត់ដំបង ថាតើអ្នកមីងបានរៀបការនឹងនៅទីកន្លែងនារីក៏នៅឆ្នាំណាដែលទៅអ្នកមីង?

ខ៖ ចាសនិយយាទៅសំរាប់ខ្ញុំបានរៀបការនឹងនៅខាងស្រុករបស់ខ្ញុំ។ ហើយនិយាយទៅគឺយើងបានរៀបការតាំងពីវៀតណាមគេបានចូលមក។

ក៖ ចាសហើយចឹងនៅពេលដែលប្តីរបស់អ្នកមីងបានចូលមកសួរហើយនឹងស្តីដណ្តឹងអ្នកមីងចឹង ថាតើប្តីរបស់អ្នកមីងគាត់ដែលបានអោយអ្វីទៅកាន់អ្នកមីងដែលរឺទេអ្នកមីងនៅពេលដែលរៀបការនឹងអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់មួយនឹងគឺដូចថាចាស់ទុំគាត់បានចូលស្ដួរ យើងនឹងហើយនឹងនៅក្នុងជំនាន់នឹងគឺគេបានចាយជាអង្ករចឹងហាសដចាស។

ក៖ ចាសហើយចឹងដូចថាសនៅពេលដែលគេបានចងអង្ករនឹងគឺជាភ្ញៀវដែលយើងបានហៅគាត់មកមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺគេបានអោយអង្ករនឹងសំរាប់ចងដៃយើង។ ហើយសំរាប់នៅក្នុងជំនាន់នឹងគឺគេមិនទាន់មានលុយអោយមកចាយនោះទេ។ ហើយប្រសិនជាគេមិនបានចងជាអង្ករនោះទេ គឺគេបានចងដៃយើងនឹងគឺជាមាសសុទ្ធតែម្តង។នឹងសំរាប់នៅក្នុងជំនាន់នឹង។

កៈ ចាសហើយចឹងនៅពេលដែលយើងបានរៀបការនឹង គឺយើងបានអញ្ជើញភ្ញៀវមកនឹងគឺយើងបានរៀបចំជាតុដូចជាល្វនឹងដែលមែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយយាទៅសំរាប់តុនឹងគឺដូចជាតុនៅខាងសាលារៀន។ ហើយគេបានរៀនចឹងហាសចាសា។

កៈ ចាសហើយចឹងនៅពេលដែលយើងបានរៀបការនឹងថាតើយើងបានរៀបការធ្វើម្ហូបអោយភ្ញៀវហូបដោយខ្លួនយើងមែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយយាទៅសំរាប់ម្ហូបសំរាប់ហូបនឹងគឺយើងបានធ្វើខ្លួនឯងចឹងហាសដចាស ពីព្រោះអីនឹងគឺមានចាស់ៗដែលគាត់នៅចាំដាំស្លរ។ ហើយសំរាប់នាក់ដែលជួយនឹងគឺសុទ្ធតែនាក់ភូមិរបស់យើងដែលពួកគាត់បានមកជួយយើងចឹងហាស។

កៈ ចាសហើយចឹងនៅពេលដែលនាក់ភូមិគាត់បានមកជួយយើងចឹងទៅ ថាតើយើងបានជួយពួកគាត់ដូចជាអង្ករអោយជាសគុណទៅពួកគាត់វិញបានខ្លះដែលរឺទេអ្នកមីង?

ខៈ ចាសនិយយាទៅសំរាប់មួយនឹងគឺមិនបានអោយពួកគាត់នោះទេ។ ពីព្រោះអីនឹងគឺសំរាប់មួយនឹងគឺដូចថាជាពួកគាត់បានជួយបងប្អូនរបស់គាត់។ ហើយនឹងដាំស្លរ។ ហើយនៅពេលដែលគេបានមកចងដៃយើងចឹងគឺដូចជារាល់ថ្ងៃសំរាប់ហូបចឹហា។ ហើយនៅក្នុងជំនាន់នឹងគឺថានៅពេលដែលគេបានហូបហើយចឹងគឺគេបានយកអង្ករនឹងយកមកចងដៃអោយយើងចឹងទៅ។

កៈ ចាសហើយចឹងបានន័យថាសំរាប់នៅក្នុងជំនាន់មុននឹងគឺគេមានអង្ករនឹងគឺច្រើនខ្លាំងណាស់មែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់នៅពេលដែលគេបានអង្ករនឹងគឺដូចថាគេបានយកទៅទិញអ្វីៗចឹងទៅ។ ហើយនៅពេលដែលបានហើយចឹងគឺដូចថាយើងនឹងបានយករបស់របបទាំងអស់នឹងគឺយើងប្តូរគ្នាដើម្បីហូបចឹងទៅហាសចាសា។

កៈ ចាហើយចឹងបានន័យថាសំរាប់របស់របបទាំងអស់នឹងនៅក្នុងជំនាននឹងគឺយើងសុទ្ធតែបានប្តូរជាអង្ករទាំងអស់បានមែនដែលរឺទេអ្នកមីង?

ខៈ ចាសៗ ហើយនិយាយទៅគឺមិនមែនយើងមានស្រាប់ដោយខ្លួនរបស់យើងនោះទេ។

កៈ ចាសហើយចឹងនៅពេលនឹងគឺយើងបានកាប់ជ្រូកដើម្បីធ្វើ ហើយនឹងរៀបចំថ្ងៃរៀបការរបស់យើងចឹងទៅមែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយាយទៅគឺយើងបានកាប់ជ្រូកចឹងទៅ ហើយនឹងបានយកបន្លែនឹងគឺលាយជាមួយនឹងដើមចេកសំរាប់ហូបចឹងទៅ។

កៈ ចាសនិយាយទៅគឺយើងស្មានតែយើងនឹងបានចិញ្ចឹមរបស់ផ្ទាល់ខ្លួនរបស់យើងចឹងហាសហើយយើងអាចយកមកធ្វើពីធីរៀបការរបស់យើងបានមែនដែលរឺទេអ្នកមីង?

ខៈ ចាសនិយយាទៅសំរាប់នៅពេលដែលខ្ញុំបានរស់នៅខាងជុំរុំនឹងគឺខ្ញុំបានចិញ្ចឹមសត្វទាំងអស់នឹងដែល។ ហើយនិយាយទៅនៅពេលដែលយើងនឹងបានរស់នៅទីកន្លែងនឹងប្រហែលជាបាន២ទៅ៣ខែនឹងគឺយើងបានរៀបការតែម្តង។

កៈ ចាសហើយចឹងនៅពេលដែលអ្នកមីងបានរស់នៅទីកន្លែងនឹងគឺគេបានស្គាល់អ្នកមីង រឺក៏យ៉ាងមិចដែលទៅអ្នកមីង?

ខៈ ចាសនិយាយទៅសំរាប់យើងទាំង២នាក់នឹងគឺបានរស់នៅក្នុងស្រុកភូមិតាំងពីតូចជាមួយនឹងគ្នា។

កៈ ចាសចឹងសំរាប់លោកពូគាត់មិនបានមកខាង ខេត្ត បាត់ដំបងជាមួយនឹងអ្នកមីងនោះទេមែនដែលរឺទេអ្នកមីង?

ខៈ ចាសគឺប្តីរបស់ខ្ញុំនឹងគឺគាត់មិនបានមកជាមួយនឹងខ្ញុំនោះទេ។ ហើយនិយាយទៅគឺគាត់បានរស់នៅស្រុករបស់គាត់។

កៈ ចាសហើយចឹងចង់សួរអ្នកមីងបន្តិចថាសំរាប់នៅក្នុងជំនាន់នឹងថាតើហេតុអ្វីដែលទៅបានជាគេបានយកតែ អ្នកមីងយកមកបាត់ដំបងដែលទៅអ្នកមីង?

ខៈ ចាសហើយនិយាយទៅសំរាប់ពេលនឹងគឺគេមានកងចល័តនឹងគឺផ្សេង។ ហើយណាមួយទៀតនឹងគឺគេកំពុងរើស។ ហើយសំរាប់យើងនឹងក៏បានជួយការងាររបស់គេជួយធ្វើល្ហហើយនឹងលើកប្រលាយ។ ហើយណាមួយទៀតនឹងគឺគេបានធ្វើប្រវត្តរូបយើងដែល។ ហើយសំរាប់១០ថ្ងៃនឹងគឺគេបានធ្វើម្តងៗ។ ហើយសំរាប់យើងនឹងគឺថានៅពេលដែលឆ្លើយនឹងគឺមានតែពាក្យដ៏ដែលចឹងហាស ហើយណាមួយទៀតនឹងគឺយើងមិនមាននិយាយទៅគឺក្រឡាច់សំដីដូច

គេនោះទេ។ ហើយសំរាប់១០ថ្ងៃនឹងគឺគេបានធ្វើប្រវត្តិរូបយើងម្តង។ ហើយគេបានសួរម្តាយរបស់យើង។ ហើយដូចថាគេបានមកសំភាសន៏យើងនឹងដូចជាប្អូនបានសួរខ្ញុំ។ ហើយនិយាយទៅគឺគេបានអោយយើងនឹងគឺឆ្លើយដ៏ដែល។ ហើយណាមួយទៀតនឹងគឺថានៅពេលដែលយើងនឹងបាននិយាយដ៏ដែលចឹងគឺពួកវានឹងបានថាយើងនឹងគឺជានាក់ដែលមានភាពស្មោះត្រង់សំរាប់ពួកគាត់។ ហើយនៅពេលដែលយើងមានភាពស្មោះត្រង់ចឹងគឺគេបានរើសយើងនឹងមកធ្វើការងារនៅខាងរោងចក្រ។ ហើយសំរាប់ម្តាយរបស់យើងនឹង ហើយនឹងឪពុករបស់យើងនៅក្នុងជំនាន់ពីដើមនឹងគឺគាត់ធ្វើការងារផ្នែកស្រែហើយនឹងចំការ។ ហើយណាមួយទៀតនឹងគឺយើងមិនបានធ្វើជាទាហ៊ានអ្វីនោះទេ។ហើយដល់ពេលចឹងទៅ សំរាប់នាក់មានភាពស្មោះត្រង់ជាមួយនឹងគេចឹងទៅគឺគបានរើសម្នាក់នឹងអោយទៅធ្វើការងារនៅខាងរោចក្រចឹងទៅ។

ក៖ ចាសហើយចឹងនៅពេលដែលឪពុកហើយនឹងម្តាយរបស់យើងគឺគាត់ពួកគាត់បានធ្វើការងារផ្នែកជាទាហ៊ានចឹងទៅ ថាតើគេបានយកយើងនឹងទៅធ្វើការងារខាងនឹងដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់មួយនឹងគឺគេមិនបានយកយើងនោះទេ។

ក៖ ចាសហើយចឹងសំរាប់បងប្អូនរបស់អ្នកមីង គឺគេមិនបានយកមកជាមួយនឹងអ្នកមីងនោះទេមែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ

ក៖ ចាសហើយចឹងសំរាប់ការងារនៅខាងរោងចក្រនឹងថាតើគេបានធ្វើការងារតែស្រីៗនោះទេរឺក៏យ៉ាងមិចដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ការងារទាំងអស់នឹងគឺគេបានធ្វើការងារទាំងប្រុសការងារទាំងស្រីនឹងគឺគេ អោយធ្វើទាំងអស់។ តែគ្រាន់តែយើងនឹងនៅខាងកងចល័តនឹងគឺផ្សេងៗគ្នា។ ហើយយើងនៅក្រោមការគ្រប់គ្រងគេទៀត។ហើយដល់ពេលចឹងគឺយើងមិនអាចទៅធ្វើអ្វីតាមចិត្តរបស់យើងបាននោះទេ។

ក៖ ចាសហើយចឹងនៅពេលដែលបែកចែកហើយចឹងគឺយើងក៏បានរស់នៅផ្សេងៗគ្នាតែម្តងមែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ

ក៖ ចាសហើយចឹងសំរាប់បងប្រុសរបស់អ្នកមីង ថាតើគាត់បានរៀបការននឹងនៅទីកន្លែងណាដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់បងប្អូនរបស់ខ្ញុំនឹងគឺគាត់បានរៀបការនឹងគឺតាំងពីជំនាន់មិនទាន់មានរដ្ឋប្រហារមកម្លេស។ ហើយនិយាយទៅគឺមិនទាន់បានចូលនៅក្នុងសម័យ លុន ណល នោះទេ។ ហើយដល់ពេលចឹងគឺគាត់មិនបានមកជាមួយនឹងនោះទេ។

ក៖ ចាសហើយចឹងនៅពេលដែលនៅក្នុងជំនាន់នឹងនៅពេលដែលបានរៀបការហើយចឹង បានអ្នកមីងបានត្រឡប់មករស់នៅភូមិអង្គនឹងគឺជាមួយបងប្អូនរបស់អ្នកមីងមែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ

ក៖ ចាសហើយចឹងនៅពេលដែលអ្នកមីងបានមករស់នៅទីកន្លែងនេះនឹងគឺអ្នកមីង បានមកចាប់ដីដើម្បីបានមករស់នៅរឺក៏យ៉ាងមិចដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់ពេលនឹងគឺថាយើងនឹងបានមករស់នៅនឹងគឺមានដីគេបានអោយយើង។ ហើយនិយាយទៅគឺយើងបានតែមួយផ្ទះនោះទេ។

ក៖ ចាសហើយនៅពេលដែលអ្នកមីងបានមករស់នៅទីកន្លែង ហើយចឹងថាតើអ្នកមីងបានប្រកបមុខរបបអ្វីដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅនៅពេលលដែលយើងបានមករស់នៅទីកន្លែងនេះ គឺយើងបានលក់ត្រកួន ហើយនឹងដើរបេះត្រកួន។ ហើយនិយាយទៅគឺយើងបានដើរបេះស្ពៅចឹងទៅដើម្បីបានរបស់ទាំងអស់នឹងហើយចឹងគឺយើងបានយកទៅលក់នៅផ្សារបឹងឈូកចឹងទៅ។ ហើយណាមួយទៀតនឹងគឺយើងទទួលពីគេខ្លះចឹងទៅ។

ក៖ ចាសហើយចឹងបានន័យថាសំរាប់នៅក្នុងជំនាន់ពីមុនអ្នកមីងបានរកស៊ី ហើយនឹងលក់ដូរដែលមែនដែលរឺទេអ្នកមីង?

ខ៖ ចាស។

ក៖ ចាសហើយចឹងសំរាប់ពេលលូវនឹងថាតើ ហេតុអ្វីដែលទៅបានជាអ្នកមីងមិនបានប្រកបមុខរបបទៀតចឹងអ្នកមីង?

ខ៖ ចាសនិយាយទៅគឺដូចថាសំរាប់កូនរបស់យើងនឹងគាត់ធំៗអស់ហើយ។ ហើយណាមួយទៀតនឹងគឺគាត់ជានាក់ដើររក។ ហើយដល់ពេលចឹងគឺយើងគ្រាន់តែនៅផ្ទះចាំដាំបាយអោយពួកកូនរបស់យើងតែប៉ុននឹង។

ក៖ ចាសហើយចឹងសំរាប់កូនរបស់អ្នកមីង ៣នាក់ដែលបាននៅទីកន្លែងនឹងថាតើគាត់បានរស់នៅជាមួយនឹងអ្នកមីងដែលរឺក៏យ៉ាងមិចដែលទៅអ្នកមីង?

ខ៖ ចាសនិយាយទៅគឺសំរាប់ពួកគាត់នឹងគឺបានរស់នៅផ្សេង។ ពីព្រោះអីនឹងនៅពេលដែលគាត់បានរៀបការនឹងគឺបានទៅរស់នៅជាមួយគ្រួសាររបស់គាត់នឹងនៅឆ្ងាយៗដែល។

ក៖ ចាសហើយចឹងសំរាប់កូនរបស់អ្នកមីងដែលបានរៀបការនឹងថាតើពួកគាត់គឺជាកូនប្រុសទាំងអស់គ្នាមែនដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់កូនរបស់ខ្ញុំនឹងគឺមានប្រុសចំនួន២នាក់ ហើយសំរាប់កូនស្រីនឹងគឺចំនួន១នាក់។ ហើយសំរាប់ពួកគាត់បានទៅរស់នៅឆ្ងាយៗអស់ហើយ។

ក៖ ចាសហើយចឹងសំរាប់ពួកគាត់ថាតើគាត់ដែលបានមកលេងអ្នកមីងដែលរឺទេអ្នកមីង?

ខ៖ ចាសនិយាយទៅសំរាប់កូនខ្លះនឹងគឺគេបានមកចឹងទៅ ហើយសំរាប់កូនខ្លះគាត់រវល់ពេកចឹងទៅ។ក៏មិនបានមកលេងនោះទេ។

ក៖ ចាសហើយចឹងបានន័យថាសំរាប់រាល់ថ្ងៃនឹងគឺអ្នកមីងនៅមានបន្ទុកនឹងគឺចំនួនតែ៣នាក់នោះទេ តែសំរាប់ពួកគាត់បានទៅធ្វើការងារអស់ហើយមែនដែលរឺទេអ្នកមីង?

ខ៖ ចាសៗ។

ក៖ ចាសហើយចឹងសំរាប់អ្នកមីងមានអ្វីចង់បន្ថែមអ្វីទៀតដែលរឺទេ សំរាប់ប្រវត្តិរបស់អ្នកមីងដែលរឺទេអ្នកមីង?

ខ៖ ចាសអត់មាននោះទេ។

ក៖ ចាសហើយចឹងសំរាប់ចង់ផ្ដែលផ្ដាំទៅកាន់ក្មេងៗជំនាន់ក្រោយដែលរឺទេអ្នកមីង?

ខ៖ ចាសនិយយាទៅគឺខ្ញុំមិនសូវជាមានច្រើននោះទេ។ ហើយណាមួយទៀតនឹងគឺមិនសូវជាចេះនិយាយទៀត។

ក៖ ចាសនិយាយទៅគ្រាន់តែចង់ផ្ដាំផ្ញើអោយក្មេងៗជំនាន់ក្រោយស្ដាប់បង្គាប់ម្ដាយចឹងហាសអ្នកមីង?

ខ៖ ចាសនិយាយទៅគឺមិនសូវជាបិននិយាយនោះទេ។ ។

ក៖ ចាសហើយចឹងអត់អ្វីនោះទេអ្នកមីង ហើយចឹងអរគុណច្រើនខ្លាំងណាស់អ្នកមីងចាស ហើយចឹងជំរាបលាណាអ្នកមីង ៕